# តើដំណើរវិវត្តន៏ផ្ទុយពីច្បាប់ទី២របស់ថាមពលកំដៅដែរឬទេ?

ម៉ៅរី មីឌុដលតុន(Maury Middleton)

១៦ កុម្ភៈ ២០០៦

ច្បាប់ទី២នៃថាមពលកំដៅបាននិយាយថា ថាមពលនៅក្នុងប្រពន្ធដាច់ដោយឡែកមួយ ប្រែក្លាយពីថាមពលដែលអាចប្រើប្រាស់ ទៅជាថាមពលដែលមិនអាចប្រើប្រាស់បាន ។ នេះក៏វាទាក់ទងទៅនឹងប្រពន្ធ័សាំញ៉ាំដែរដែលបង្កឱ្យមានលំដាប់មិនត្រឹមត្រូវ ។ កំរិតនៃភាពគ្មានលំដាប់នេះ គឺជាលក្ខ័ណ្ឌមួយដែលទាក់ទងទៅនឹងច្បាប់នេះ ហើយវាក៏ជាខ្នាតរង្វាស់នៃភាពគ្មានលំដាប់នេះដែរ ។ ដូច្នេះអាស្រ័យទៅលើពេលវេលានេះនោះបង្កឱ្យ កំរិតនៃភាពគ្មានលំដាប់នេះកាន់តែកើនឡើងថែមទៀត ។ អ្វីៗទាំងអស់ផ្លាស់ទីពីតំបន់ដែលមានប៉ូតង់ស្យែលខ្ពស់ ទៅតំបន់ដែលមានប៉ូតង់ស្យែលទាប ។ ចំពោះអាគុយដែលសាកភ្លើងពេញមានបរិមាណ អេឡិចត្រុងបរិបូរ នៅផ្នែកខាងប៉ូលអវិជ្ជមាន ។ រីឯនៅត្រង់ប៉ូលវិជ្ជមានមានបរិមាណប្រូតុង នៅក្នុងកំរិតស្មើទៅនឹងអេឡិចត្រុងដែរ ។ អញ្ចឹង យើងមានប៉ូតង់ស្យែលអគ្គិសនីដែលអាច ធ្វើដំណើរការបានហើយ ។ យើងក៏អាចអនុវត្តន៍ទ្រឹស្តីនេះទៅលើថាមពលផ្សេងទៀតដែរ ។ ទោះបីជាច្បាប់នេះអនុវត្តន៏ជាមួយនឹងថាមពលក៏ដោយ វាក៏អាចអនុវត្តន៏ទៅលើផ្នែកដទៃទៀតនៃវិទ្យាសាស្ត្រដូចជា គីមីវិទ្យា ជីវវិទ្យា តារាសាស្ត្រ -ល- ផងដែរ ។ ដោយហេតុថាដំណើរវិវត្តន៏ ទាមទារឱ្យការកើនឡើងនូវប្រពន្ធ័ដែលមានលំដាប់មួយ ដោយចាប់ផ្តើមឡើងជាមួយរូបធាតុគីមីជាមូលដ្ឋាន ហើយអភិវឌ្ឍន៏ឡើងក្លាយទៅជាសាពាង្គកាយមានជីវិតដ៏ស្មុគស្មាញមួយ ដូចដែលយើងឃើញរាល់ថ្ងៃនេះ គឺជាច្បាប់ទី២ដែលត្រូវបានប្រើដើម្បីជំរុញដល់សំទុះនៃទ្រឹស្តីដំណើរវិវត្តន៏ផ្នែកជីវសាស្ត្រ ។ ទោះបើយ៉ាងនេះក៏ដោយ មនុស្សជាច្រើនយល់ឃើញថាគ្មានភាពចំរុងចំរាស់គ្នាបន្តិចសោះ ដោយព្រោះលក្ខណ្ឌ័សំរាប់និយមន័យនេះ ទាមទារឱ្យមានប្រពន្ធ័ដាច់ដោយឡែកពីគ្នាមួយ ។ ភពផែនដីទទួលបានថាមពលទាំងស្រុងមកពីព្រះអាទិត្យ មិនមែនបង្កើតឡើងជាប្រពន្ធ័បិទឡើយ ។

ឧទាហរណ៏ដែលត្រូវបានគេប្រើប្រាស់ជាច្រើនដងនោះ គឺនិយាយអំពីគ្រឿងម៉ាស៊ីនឡាន ។ នៅពេលដែលវាបានទទួលថាមពលមកពីធុងហ្គាស(ប្រៀបដូចជាព្រះអាទិត្យបង្ហូរថាមពលរបស់វាមកផែនដីដែរ) ចំហេះរបស់ឥន្ធនៈត្រូវបានបំប្លែងទៅជាកំដៅ ហើយបំភាយចេញមកធ្វើឱ្យពិសស្តុងមានចលនា ។ ចលនានេះបានបំប្លែងដើម្បីបង្វិលថាមពលបានការតាមរយៈវីឡប្រីកាំង ។ ថាមពលបានការនេះគឺមាន(ជាច្បាប់ទី២នៃកំដៅនិយាយថា ត្រូវតែតិចជាង) ថាមពលដែលចេញពីឥន្ធនៈ ដែលបង្ហូរចូលមកក្នុងគ្រឿងម៉ាស៊ីនបាត់បង់ ។ ការបង្ហាញនេះអាចយកទៅប្រើបានដែរក្នុងគ្រប់មធ្យោបាយទាំងអស់ចំពោះកង់រ៉ៃ ដែលជំហាននិមួយផ្តល់នូវលទ្ធផល ពីការបាត់បង់ថាមពលបានការ ដោយព្រោះកំដៅ ការកកិត បន្ទុកអេឡិចត្រូនិច ការបូម -ល- ។ ប៉ុន្តែប្រព័ន្ធនេះនៅតែដំណើរការដដែលពីព្រោះនៅតែបន្តចូលទៅក្នុងម៉ាស៊ីន ដើម្បីបន្ថែមឱ្យកំដៅដែលបានបាត់បង់ទៅ ។ ហើយទ្រឹស្តីបទនេះក៏អនុវត្តន៏ចំពោះ ផែនដីដែរ ។ ព្រះអាទិត្យបានបញ្ជូនផែនដីជាមួយនឹង ថាមពលម៉ាញេទិចដែលត្រូវបានបំប្លែង តាមរយៈការសំយោគពន្លឺព្រះអាទិត្យឱ្យទៅជាទំរង់ផ្សេងៗទៀត ។ ទោះបើជាមានការបាត់បង់ថាមពលតាមដំណើរការនេះក៏

ដោយ ក៏វានៅតែមានការផ្គត់ផ្គង់បានគ្រប់គ្រាន់ដដែល ។ យើងអាចកត់សំគាល់ឃើញថា តាមរយៈការពង្រីកប្រពន្ធ័ដោយបូករួមទាំងព្រះអាទិត្យផងនោះ ជាចុងក្រោយវានឹងមានឱនភាព ដូចជាយើងអាចបញ្ចូលធុងហ្គាសទៅ ក្នុងឡានមួយដែរ ។ ថាមពលដែលទទួលបានពីព្រះអាទិត្យគឺមានទំហំធំ ហើយយើងក៏ប្រើប្រាស់ការកាត់បន្ថយថាមពលបានតិចតួចនៅក្នុងជីវិតរបស់យើង ហើយចំនុចដែលសំខាន់នោះគឺថា វាដើរទ្រឹស្តីនៃច្បាប់ទី២ ហើយក៏មានការថយចុះដែរ ។

ចំពោះអ្នកដែលលើកទ្រឹស្តីនេះឡើងមកគឺមានការ យល់ខុសហើយ ថាហេតុអ្វីច្បាប់ទី២នេះខុសអំពីច្បាប់នៃដំណើរវិវឌ្ឍន៍របស់ជីវសាស្ត្រ ។ យើងចាំបាច់ត្រូវតែសំឡឹងមើលទៅប្រពន្ធ័នេះទៀត ដោយលើកយកនូវទស្សនៈពីរផ្សេងគ្នា ។ ជាដំបូងយើងនឹងពិនិត្យទៅលើទស្សនៈមួយអំពីថាមពល ហើយមួយទៀតទស្សនៈអំពីលំដាប់ ។

យើងបានបង្ហាញរួចហើយថា ភពផែនដីមិនមែនជាប្រពន្ធ័បិទជិតនោះទេ ។ ហើយយើងក៏ត្រូវសំឡឹងមើលឱ្យហួសពីហ្នឹងទៀតដែរ ។ ប្រពន្ធ័សូឡារបស់យើងគឺពិតប្រាកដណាស់ វាជាប្រពន្ធ័បិទដែលមិនទទួលយកថាមពលដែលមកពីប្រភពខាងក្រៅ ។ ប៉ុន្តែសូមឱ្យមើលហួសពីនេះ ហើយពិចារណាអំពីសកលលោកទាំងមូល ។ ទ្រឹស្តីនៃដំណើរវិវត្តន៍បានឱ្យនិយមន័យថា សកលលោកនេះគឺបានកកើតឡើងជាប្រពន្ធ័ដែលមានកំណត់មួយ ហាក់ដូចជាស៊ុតនៃលោហធាតុមួយដែលបានផ្ទុះញាស់ឡើងកាលពី១៥វយកោដិឆ្នាំមុន ។ ចាប់តាំងពីពេលនោះមកសកលលោកក៏បានរីកដុះដាលធំឡើង ។ តាមរយៈទ្រឹស្តីនេះ នោះសកលលោកនេះគឺជាប្រពន្ធ័បិទជិត ។ ដូច្នេះចាប់តាំងពីដើមដំបូងមក ថាមពលបានការក៏ចាប់ផ្តើមបាត់បង់ទៅហើយ ដោយផ្លាស់ប្តូរចលនាពីតំបន់ដែលមានកំរិតប៉ូតង់ស្យែលខ្ពស់មកជាកំរិតសមតាវិញ ។ ដើម្បីឱ្យងាយយល់ពីស្ថានភាពនេះ យើងអាចប្រៀបធៀបទៅនឹងកាហ្វេក្តៅមួយពែងនៅក្នុងបន្ទប់បិទជិតមួយ ។ ឧបមាថាបន្ទប់គឺជាប្រពន្ធ័បិទជិតមួយ ថាមពលកំដៅដែលផ្ទេរទៅដល់បរិយាកាសជុំវិញរហូតដល់ចំនុចសមតា ។ វាគ្មានថាមពលដែលបាត់បង់ឡើយ គឺមានតែបំលាស់ប្តូរថាមពលពីខ្ពស់ទៅតែប៉ុណ្ណោះ ។ កំដៅភាយចេញពីពែងកាហ្វេ បានធ្វើឱ្យកាហ្វេត្រជាក់ ។ ក្នុងពេលជាមួយគ្នាដែរកំដៅបានបន្សាយចូលមកក្នុងខ្យល់ ហើយធ្វើឱ្យខ្យល់ក្តៅ ។ ដំណើរការបន្តដូចនេះរហូតដល់សីតុណ្ហភាពឈានមកដល់ចំនុចសមតា ដែលជាចំនុចនៃវត្ថុទាំងពីរនេះមានសីតុណ្ហភាពដូចគ្នា ។ នៅត្រង់ចំនុចនេះ គ្មានប៉ូតង់ស្យែលឬថាមពលបានការទៀតទេ ហើយប្រពន្ធ័វាក៏ឈប់ដំណើរការទៀតដែរ ។ នេះក៏ជាអ្វីដែលកើតឡើងនៅក្នុងសកលលោកដែរ ហើយជាទូទៅវាសំដៅទៅលើចំនុចអសុពលភាពនៃកំដៅ ជាចំនុចដែលលែងមានថាមពលបានការសំរាប់ធ្វើការអ្វីទៀត ។ ដូច្នេះសកលលោកទាំងមូលតែជាប់គាំងស្លាប់មិនខាន ។ ខ្ញុំមិនមែនកំពុងតែព្យាយាមព្យាករណ៏អំពីថ្ងៃអវសាន្តណាមួយទេ-ដោយហេតុថាប៉ូតង់ស្យែលនៃថាមពលមានទំហំធំណាស់ ហើយវាក៏មិនបានឈានមកដល់ថ្ងៃអវសាន្តនៃកំដៅ ជាយូមកហើយ ។ ខ្ញុំគឺគ្រាន់តែព្យាយាមទាញយកចំនុចទិសដៅមួយតែប៉ុណ្ណោះ ។

ជំនួសឱ្យការដែលសំឡឹងមើលទៅអនាគតដែលជា ថ្ងៃអវសាន្តនៃកំដៅ នោះចូរឱ្យយើងមើលត្រឡប់មកក្រោយវិញដែលជាអតីតកាល ។ ដូចជាដឹងហើយថា ប៉ូតង់ស្យែលរបស់ថាមពលគួរតែមានឱនភាពដោយព្រោះពេលវេលាដ៏យូរ នោះយើងអាចសន្និដ្ឋានបានថា ប៉ូតង់សៃយលនេះគឺប្រាកដជាមានទំហំធំជាងកាលពីម៉្សិលម៉ិញ ឆ្នាំមុន

និងសតវត្សមុនដែរ ។ ត្រឡប់មកមើលអំពីឧទាហរណ៏នៃអាគុយមួយវិញ យើងអាចសាកវាឱ្យចូលមកដល់ចំនុចដែលមានប៉ូតង់ស្យែលពេញ ។ ឧទាហរណ៏ថាវាអាចចល័តអេឡិចត្រុងទាំងអស់ ចេញពីប៉ូលវិជ្ជមាន ទៅកាន់ប៉ូលអវិជ្ជមាន ។ នោះវាប្រាកដជាអាចបង្កើតនូវប៉ូតង់ស្យែលអតិបរិមាមួយ ។ មួយវិញទៀត យើងមានកាលកំណត់ច្បាស់លាស់ក្នុងការដែលសំលឹងត្រឡប់មកមើលអតីតកាលវិញ ។ ហើយចំពោះសកលលោកយើងវិញក៏មានស្ថានភាព ដូចគ្នានេះដែរ ។ ប្រសិនបើយើងត្រឡប់មើលទៅឯអតីតកាលឆ្ងាយប៉ុណ្ណា នោះថាមពលក៏មានប៉ូតង់ស្យែលក៏ធំកើតនោះដែរ ដែលជាចំនុចយើងមិនអាចរកប៉ូតង់ស្យែលឱ្យធំជាងហ្នឹងបានទេ ។ និយាយបែបនេះវិញថា សកលលោកមិនមែនគ្រាន់តែតំរង់ឆ្ពោះទៅរកពេលវេលានៃ "អវសានកំដៅ"ប៉ុណ្ណោះទេ តែវាក៏ត្រូវតែមានចំនុចចាប់ផ្ដើមដែរជាចំនុចដែលប៉ូតង់ស្យែលស្ថិតនៅត្រង់ចំនុចអតិបរិមា ។ ម្ដងទៀត ខ្ញុំមិនមែនបំណងព្យាយាមនិយាយអំពីគំរោងនៃពេលវេលាណាមួយឡើយ គឺខ្ញុំគ្រាន់តែចង់ថា វាមានពេលចាប់ផ្ដើម និង បញ្ចប់ប៉ុណ្ណោះ ។

ឥឡូវនេះសូមមើលទៅឯឧទាហរណ៏មួយទៀត ដែលវានឹងជួយឱ្យអ្នកយល់កាន់តែច្បាស់ ។ ចូរយើងពិចារណាមើលអំពីនាឡិកាប្រើថ្មមួយ ។ នៅពេលដែលនាឡិការដើរ នោះថាមពលក៏ចាប់ផ្ដើមថយចុះ ។ ថាមពលនេះត្រូវបានផ្ទេរទៅឱ្យល្បឿន ហើយនិងដៃ ហើយនៅទីបំផុតវាក៏អស់ ។ មានន័យថា វានឹងមានពេលដែលនាឡិកានឹងត្រូវងាប់ ។ សូមពិចារណាថា ខ្ញុំចាត់ទុកនាឡិកានេះថាជាប្រព័ន្ធបិទមួយ ដែលនឹងគ្មានថាមពលណាអាចផ្ដល់ឱ្យមកពីប្រភពខាងក្រៅបានទេ ។ ដូចនេះវានឹងបង្កើតឱ្យមានបញ្ហារញេរញៃមួយ ។ ប្រសិនបើច្បាប់ទី២នៃថាមពលកំដៅ ព្យាករណ៏អំពីចំនុចចាប់ផ្ដើម និងចំនុចបញ្ចប់ ហើយរយៈពេលកន្លងទៅនៅក្នុងប្រពន្ធ័បិទជិតមួយ នោះថាមពលនឹងត្រូវអស់ ដូច្នេះវានឹងទទូចឱ្យមានសំនួរមួយថា តើវាត្រូវបានសាកថាមពលពីដំបូងនៅកន្លែងណាដែរ? ចំលើយជាប្រាកដចំលើយដ៏សមញ្ញមួយប៉ុណ្ណោះ ។ វាគឺមិនអាចទៅរួចដែលប្រពន្ធ័នោះវា ចេះសាកថ្មដោយខ្លួនឯងកើត វាដាច់ខាតត្រូវតែមានម្នាក់ផ្សេងទៀតនៅខាងក្រៅប្រពន្ធ័បិទនេះ បានដាក់បញ្ចូលថាមពលទៅឱ្យប្រពន្ធ័មួយនេះ ។ នាឡិកាមិនចេះសាកថ្មដោយខ្លួនឯងបានឡើយ ។

នៅពេលដែលយើងអនុវត្តន៏នូវទស្សនៈ ជាមួយនឹងសកលលោក នោះយើងៀានសន្និដ្ឋានរួចហើយថាវាគួរតែមានចំនុចចាប់ផ្ដើមហើយនិងទីបញ្ចប់ ថេរវេលានៃដំណើរការរបស់ថាមពលជួបប្រទះនឹងឱនភាព ។ បើដូច្នេះតើសកលលោកនេះ"ត្រូវបានបញ្ចូលថាមពលឱ្យ"ពីចំនុចដំបូងបង្អស់ដោយរបៀបណា? ម្ដងទៀត ច្បាប់ធម្មជាតិ ហាមដាច់ខាតមិនឱ្យប្រពន្ធ័មួយសាកថ្មដោយខ្លួនវាបានឡើយ ដូច្នេះសេចក្ដីសន្និដ្ឋានមួយដែលត្រូវការ គឺថាមពលបានមកពីប្រភពខាងក្រៅ ។ អ្នកអាចនិយាយថា ជាថាមពលអធិធម្មជាតិ ឬ ព្រះជាអ្នកដាក់ប្រព័ន្ធមួយនេះឱ្យមានចលនា ។

នៅត្រង់ចំនុចនេះមនុស្សមួយចំនួនអាចនឹងសួរថា តើនណាជាអ្នកបង្កើតព្រះ? តាមពិតទៅមានមធ្យោបាយជាច្រើនដើម្បីឆ្លើយទៅនឹងសំនួរនេះ ។ ត្រឡប់ទៅមើលអំពីនាឡិកាប្រើថ្មវិញ ថាមពលអាចចេញមកពីខ្ញុំខ្លួនឯង ក្នុងពេលដែលខ្ញុំបញ្ចូលវាទៅឱ្យនាឡិកា នេះមានន័យថាចាំបាច់ខ្ញុំត្រូវតែមានថាមពលច្រើនជាងនាឡិកា ។ ក៏ដូចគ្នាដែរ យើងអាចសន្និដានបានថាព្រះប្រាកដតែមានថាមពលច្រើន ឬ ខ្លាំងជាងសកលលោកទាំងមូលនេះ ។ បើអញ្ចឹងតើព្រះមានប្រភពមកពីណា? ល្អ ចំលើយមួយគួរតែមានព្រះដែលធំជាងហ្នឹងម្នាក់ទៀត ដែលប្រទានឱ្យព្រះ

នោះមានថាមពលដើម្បីផ្តល់ឱ្យប្រព័ន្ធនេះ ។ ប៉ុន្តែតើអ្នកណាដែលបង្កើតព្រះដែលធំជាងមួយអង្គនេះមក? ម្តងទៀត ចំលើយគឺងាយស្រួលទេ គឺត្រូវតែមានព្រះដែលធំជាង ព្រះដែលធំជាងនេះមួយអង្គទៀតជាអ្នកដែលផ្តល់ឱ្យព្រះមួយអង្គនោះមានថាមពល សំរាប់ផ្តល់ទៅឱ្យព្រះនោះ ក្នុងការបញ្ចូលថាមពលទៅឱ្យប្រព័ន្ធសកលលោក ។ យើងអាចបន្តស្វែងរកចំលើយតទៅទៀត ដោយប្រើពាក្យថាព្រះដែលធំជាង រហូតទាល់តែដល់ចំនុចជាក់លាក់មួយបាន ។ ហើយជាចុងក្រោយវានឹងប្រាប់យើងថា គឺមានព្រះមួយអង្គដែលព្រះចេស្តា(ថាមពល)គ្មានព្រំដែននឹងកំនត់បាន ។ ការពន្យល់លើកទី២ គឺជាការពន្យល់មួយដែលងាយស្រួលយល់ជាង ។ ជំនួសឱ្យនិយាយពាក្យថាព្រះធំជាង១នេះ គឺថាមានព្រះប្រកបដោយព្រះចេស្តាគ្មានកំណត់មួយអង្គ ។ ហើយនៅក្នុងគំនិតរបស់ខ្ញុំ ខ្ញុំគិតថាការពន្យល់នេះគឺសមរម្យជាង ។

ចំនុចទី២គឺជាលំដាប់ដ៏គួរឱ្យសាំញ៉ាំមួយ នៅក្នុងប្រព័ន្ធមានជីវិត ។ ប្រព័ន្ធដ៏សាំញ៉ាំមិនមែនកើតចេញពីភាពសាំញ៉ាំឡើយ ពួកវាខូចដោយព្រោះតែបាត់បង់មុខងារ រហូតទាល់តែវាមិនអាចធ្វើការរបស់វាបានត្រឹមត្រូវទៀត ។ ចូរយកឧទាហរណ៍ពីឡានមួយគ្រឿងម្តងទៀត ។ ដោយរយៈពេលយូរទៅ ឡានវានឹងខូចហើយចាប់ផ្តើមបែកបាក់ ។ នៅពេលដែលមានបញ្ហាកើតឡើង នោះយើងអាចយកទៅហាងដើម្បីឱ្យគេជួសជុល ។ ប៉ុន្តែតើវានឹងក្លាយទៅជាដូចម្តេចវិញបើខ្ញុំយកទៅឯសួនសត្វមួយ ហើយអនុញ្ញាតិឱ្យហ្វូងស្វារើកកាយលើវា ។ វាប្រាកដជាមិនមែនជាសំនួរទេថាស្វាមានថាមពលច្រើន ប៉ុន្តែតាមពិតពួកវាខ្វះនូវប្រាជ្ញា ។ ចំនុចមួយយើងយល់ថារបស់ទាំងអស់ខូច យើងអាចសួរថាតើយើងអាចរកបានឡានថ្មីវិញដោយរបៀបណា ។ ឡានមិនមែនបង្កើតឡើងមកដោយសារខ្យល់ព្យុះ ឬ ខ្យល់គួចនោះទេ ប៉ុន្តែគឺជាមនុស្សដែលមានប្រាជ្ញា ជាអ្នកដែលរៀបចំយ៉ាងប្រុងប្រយ័ត្នចំពោះទ្រង់ទ្រាយនិមួយ១របស់វានៅក្នុងដំណើរការកម្មន្ត ។

ដើម្បីបង្កើតប្រព័ន្ធដ៏សាំញ៉ាំមួយ នោះត្រឹមតែថាមពលដើមគឺមិនគ្រប់គ្រាន់ទេ ។ ផែនដីមិនមែនជាប្រព័ន្ធបិទជិត យើងទទួលបានថាមពលស្ទើរតែទាំងអស់មកពីព្រះអាទិត្យ ។ ប៉ុន្តែអ្នកត្រូវតែមានមធ្យោបាយក្នុងចាប់យករក្សាទុក និង បំលែងថាមពលនោះ ដូចជានៅក្នុងករណីរថយន្តមួយគ្រឿងដែរ ។ អ្នកអាចចាក់សាំង ម្សៅរំសេវ ឬអ្វីទាំងអស់ក៏បានចូលទៅក្នុងឡាននោះតាមដែលអ្នកចង់ ប៉ុន្តែលុះត្រាណាអ្នកគ្រឿងម៉ាស៊ីនដែលស៊ីគ្នាដើម្បីប្រើប្រាស់ថាមពលនោះដែរ អ្នកនឹងមិនអាចទទួលបានការងារប្រកបដោយសារប្រយោជន៍ ឬក៏ ផលិតនូវផលិតផលដែលអាចដំណើរការបានឡើយ ។ នៅក្នុងជីវវិទ្យា ពន្លឺព្រះអាទិត្យត្រូវបានរុក្ខជាតិចាប់យក ហើយតាមរយៈដំណើរសំយោគបានបំលែងវាទៅជាថាមពល ។ ទំរង់ថាមពលគីមីដែលទើបតែកកើតថ្មីនេះ ត្រូវបានមនុស្ស និង សត្វស៊ីតាមរយៈប្រពន្ធ័រំលាយអាហារ ដើម្បីទ្រទ្រង់ជីវិត ។ ប្រព័ន្ធនេះវាធ្វើការបានល្អណាស់ ពីព្រោះថាប្រព័ន្ធមេកានិចដ៏សាំញ៉ាំទាំងអស់ស្ថិតនៅកន្លែងត្រឹមត្រូវ ។ ប៉ុន្តែតើថាមពលព្រះអាទិត្យអាចផ្ទេរចូលទៅឱ្យប្រភពនៃប្រព័ន្ធមេកានិចទាំងនេះបានដែរឬទេ? ឡានមានដំណើរការ ពីព្រោះតែអ្នកច្នៃម៉ូតដ៏មានប្រាជ្ញា ដែលបង្កើឱ្យមានប្រព័ន្ធប្រើប្រាស់ថាមពលហើយបំលែងវាឱ្យទៅជាផលិតផលដែលអាចប្រើប្រាស់បានយ៉ាងមានប្រយោជន៍ ។ ដែលមានពន្លឺព្រះអាទិត្យ ឬពន្លឺគ្រប់គ្រាន់ក្នុងការផលិតគ្រឿងផ្ទេរអគ្គិសនីដ៏ធំ១ នឹងមិនអាចផលិតចេញជាអនុផលសំណង់បានឡើយ ។ ប្រសិនបើ

ថាមពលជាតំរូវទាំងស្រុងសំរាប់ផលិតលំដាប់សាំញ៉ាំ នោះតើហេតុអ្វីបានជាយើងមិនឃើញខ្យល់ពុះ ខ្យល់គួច ឬក៏ព្យុះរន្ទះផលិតប្រពន្ធ័សាំញ៉ាំដែលមានមុខងារជាក់លាក់ដែរទៅ? ថាមពលដើម គឺមិនគ្រប់គ្រាន់សំរាប់ផលិតលំដាប់បានឡើយ ។ វាចាំបាច់ត្រូវតែមានអ្នកដែលប្រកបដោយប្រាជ្ញម្នាក់ជាអ្នកធ្វើ ។

ពេលមួយពួកអ្នកវិវត្តនិយមបានអះអាងថា ប្លង់ដ៏ប្រកបដោយប្រាជ្ញានោះមិនអាចនឹងរកឃើញឡើយ ។ នៅពេលដែលយើងគិតដល់បភពនៃជីវិត នេះគឺជាអ្វីដែលជាការពិតណាស់ ។ ទោះជាយ៉ាងណាក៏ដោយ យើងក៏អាចនិយាយបានដូចគ្នាចំពោះដំណើរវិវត្តន៏ ។ យើងមិនដែលធ្វើការសង្កេតមើលពីជីវិតនេះ ថាចេញមកពីវត្ថុដែលគ្មានជីវិតឡើយ ។ ប៉ុន្តែអ្វីដែលយើងអាចសំឡឹងមើលទៅបាន គឺជាអ្វីដែលយើងសង្កេតមើលនាសព្វថ្ងៃនេះ ។ មានឧទាហរណ៏រាប់រយកោដិអំពីប្រពន្ធ័ដ៏សាំញ៉ាំដែលកំពុងតែត្រូវបានបង្កើតនាពេលសព្វថ្ងៃនេះ ទាំងអស់នោះសុទ្ធតែជាដំណើរការដែលប្រកបទៅដោយប្រាជ្ញាញាណ ។ ទោះជាយ៉ាងក៏ដោយខ្ញុំជំរុញឱ្យម្នាក់ៗ កត់ត្រាទុកជាឯកសារថាប្រពន្ធ័សាំញ៉ាំត្រូវបានបង្កើតឡើងចេញពីថាមពលដើម ហើយនិង ដំណើរការធម្មជាតិ ។

មានកត្តាដ៏សំខាន់មួយទៀតអំពីប្លង់ដ៏ប្រកបដោយប្រាជ្ញា ។ គំនិតនៃមុខងារមុនពេលបង្កើត គឺជាគ្រឹះដ៏សំខាន់ចំពោះឧស្សាហកម្មកែច្នៃ ។ ពិតណាស់របស់ទាំងអស់ ដែលបានបង្កើតឡើងមកត្រូវបានមានរូបរាងរួចទៅហើយនៅក្នុងគំនិតរបស់មនុស្សម្នាក់ ។ ដំណើរការកែច្នៃ ចាប់ផ្តើមឡើងជាមួយនឹងការកំណត់អំពីមុខងារឬគោលបំណង ។ ហើយក្រោយមកអ្វីៗទាំងអស់ពាក់ពន្ធ័ទៅនឹងគោលបំណងនេះឯង ។ គោលបំណងនេះមិនមែនត្រូវបានកំណត់ឡើងដោយ ឧបករណ៏ក្នុងកំឡុងពេលដែលកំពុងតែបង្កើតឡើយ ប៉ុន្តែគឺតាមរយៈអ្នកបង្កើតវា ។ ផ្ទុយមកវិញព្រឹត្តិការណ៏នៃឱកាសដ                                        កំរ  មិនស្ថិតនៅក្នុងគោលបំណងនៃការកែច្នៃឡើយ ។

ប្រសិនបើខ្ញុំប្រាប់អ្នកត្រឹមតែមួយផ្នែកនៃភស្តុតាង ហើយអ្នកជឿវា នោះបានន័យថាអ្នកមិនបានទទួលការបង្រៀនអ្វីបន្តិចសោះឡើយ គឺអ្នកស្ថិតនៅក្នុងការបញ្ចុះបញ្ចូលវិញ ។ ប្រសិនបើខ្ញុំប្រាប់អ្នកនូវភស្តុតាងទាំងអស់ រឺឯធ្វើការសំរេចចិត្ត នោះបានន័យថាអ្នកទទួលបានការបង្រៀនហើយ ។